**គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប**

**Tonle Sap Technology Demonstrations for Productivity Enhancement**

(TSTD - TA 7305-CAM)

# សៀវភៅណែនាំបច្ចេកទេសស្តីពី

# ដំណាំសណ្តែកបាយ លើដីស្រែ មុន និងក្រោយស្រូវវស្សា



*ខែ សីហា ឆ្នាំ ២០១៣*

# តារាងមាតិកា

**អារម្ភកថា**………………………………………………………………………… 1

**១.សេចក្តីផ្តើម**………………………………………………………………………… 2

**២.ការដាំដុះដំណាំសណ្តែកបាយ** …………………………………………………………2

២-១. ពូជសណ្តែកបាយដែលនិយមប្រើប្រាស់ …………………………………………… 2

២-២. ការជ្រើសរើសពូជ និងការរៀបចំគ្រាប់មុនដាំ…………………………………………… 3

២-៣- ការរៀបចំធ្វើជីកំប៉ុស្ត……………………………………………………………… 3

២-៣.១ វត្ថុធាតុផ្សំធ្វើជីកំប៉ុស្តគោក

២.៣.២. វិធីធ្វើជីកំប៉ុស្តគោក

២-៤. វិធីសាស្ត្រដាំដុះ………………………………………………………………… 5

២-៤-១. ការដាំដុះដោយបុកជារណ្តៅ

២-៤-២. ការដាំដោយឆូតគន្លងជាជួរ

២-៤-៣. ការដាំដោយព្រួស

២-៥. ការដករំលស់កូន…………………………………………………………………… 7

២-៦. ការប្រើប្រាស់ជី ……………………………………………………………………… 8

២-៦-១. ជីគីមី

២-៦-២. ជីលាមកគោ និងជីកំប៉ុស្ត

២-៧. ការកំចាត់ស្មៅចង្រៃ………………………………………………………………… 9

២-៨. ជម្ងឺ និងសត្វល្អិតលើដំណាំសណ្តែកបាយ វិធីការពារ និង កំចាត់ ……………………… 9

២-៨-១. ជម្ងឺសណ្តែកប្លួស

២-៨-២. ជម្ងឺអុចពណ៌ត្នោតលើស្លឹកសណ្តែកបាយ

២-៨-៣. សត្វល្អិតបំផ្លាញជញ្ជក់ជ័រ

២-៨-៣-១. ចៃ

២-៨-៣-២. ពីងពាងក្រហម
២-៨-៤. សត្វល្អិតចោះស៊ីផ្លែ និង ផ្កា
២-៨-៤-១. ដង្កូវឆ្នូតមានរោម
២-៨-៤-២. ដង្កូវមូរស្លឹក
២-៨-៥. សត្វល្អិតចោះស៊ីផ្លែ និង ផ្កា
២-៨-៥-១. សង្កើចពណ៌បៃតង
២-៩. ការប្រមូលផល …………………………………………………………………………………….. 14

២-១០. ការហាលសម្ងួតក្ទួរ……………………………………………………………. ……………………14

២-១១. ការទុកដាក់ ថែទាំគ្រាប់ពូជ…………………………………………………………………………..15

**៣. ការកត់ត្រាចំណាយចំណូលផលិតកម្ម និង វិភាគសេដ្ឋកិច្ច**……………………..15

៣.១. ការកត់ត្រាចំណាយចំណូលផលិតកម្ម ……………………………………………………….. 15

៣.២. ការប្រើប្រាស់ព័ត៌មានប្រមូលបាន សម្រាប់វិភាគចំណាយចំណូលផលិតកម្ម…………….. 17

# អារម្ភកថា

គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD) ជាគម្រោងជំនួយបច្ចេកទេស ដែលផ្តល់សហ-ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្ត ដោយរដ្ឋាភិបាលហ្វាំងឡង់ មូលនិធិជៃគូអ៊ី-អាស៊ី និងចែករំលែកពុទ្ធិនៃសាធារណរដ្ឋកូរ៉េ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ រាជរដ្ឋាភិបាលកម្ពុជាចូលរួមបដិភាគ មិនមែនជាថវិកា (ធនធានមនុស្ស ការិយាល័យបំពេញការងារ...) សម្រាប់អនុវត្តគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ីជាអ្នកចាត់ចែងប្រតិបត្តិការផ្ទាល់ ជំនួសមុខឱ្យម្ចាស់ជំនួយ ។ គម្រោងបានធ្វើការសាកល្បងបង្ហាញបច្ចេកវិទ្យាកសិកម្ម និង ផ្តល់សេវាព័ត៌មានជនបទ ដើម្បីបង្កើនប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូចក្នុងខេត្ត កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ។

គម្រោងបានអនុវត្ត *កម្មវិធីធ្វើបង្ហាញដំណាំរួមផ្សំ (សណ្តែកបាយ ពោត...) លើដីស្រែ មុន ឬ ក្រោយស្រូវវស្សា* ក្នុងខេត្តទាំងបួន ។ ដោយសហការជាមួយមន្ត្រីកសិកម្មក្នុងខេត្តទាំងបួន គម្រោងបានអនុវត្តកម្មវិធីធ្វើបង្ហាញ និងបណ្តុះបណ្តាលបច្ចេកទេសដាំដំណាំសណ្តែកបាយ លើដីស្រែ ដោយប្រើវិធីសាស្ត្របង្រៀន ឱ្យធ្វើអនុវត្តជាក់ស្តែង ជាជំហានៗ តាមដំណាក់កាល លូតលាស់ ពេញមួយវដ្តដំណាំ។ សៀវភៅណែនាំបច្ចេកទេសស្តីពី ***ដំណាំសណ្តែកបាយលើដីស្រែ មុន ឬ ក្រោយស្រូវវស្សា*** នេះ បានរៀបចំឡើងដើម្បីផ្តល់នូវចំណេះដឹង និង ចំណេះធ្វើជាក់ស្តែង ដល់កសិករ ក្នុងគោលបំណងប្រើប្រាស់ដី និង សំណើមដី និងទឹកដែលមាន ឱ្យអស់លទ្ធភាព។

ខ្លឹមសារក្នុងសៀវភៅណែនាំបច្ចេកទេសនេះ បានរៀបចំឡើង ដោយក្រុមអ្នកបច្ចេកទេស របស់គម្រោងសម្រាប់កសិករ ដោយផ្អែកលើជំហាន និង បទពិសោធន៍អនុវត្តជាក់ស្តែង កន្លងមក ក្នុងឆ្នាំ ២០១២-២០១៣។

ការអនុវត្តកម្មវិធីធ្វើបង្ហាញ និង បណ្តុះបណ្តាល ស្តីពី *កម្មវិធីធ្វើបង្ហាញដំណាំរួមផ្សំ (សណ្តែកបាយ ពោត ...) លើដីស្រែ មុន ឬ ក្រោយស្រូវវស្សា* នេះ អាចទទួលបានជោគជ័យ ដោយមានការគាំទ្រជាប់ជាបន្តពីថ្នាក់ដឹកនាំ និងបុគ្គលិកក្រុម ទីប្រឹក្សា គម្រោង ពី លោក **ប្រាក់ ថាវរមិដា** ប្រធានសម្របសម្រួលគម្រោង TSTD និង ជាអគ្គលេខាធិការរង នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង លោក **លីវ លាងហ៊ី** ប្រធានក្រុមទីប្រឹក្សាគម្រោង និង ពីមន្ត្រី បច្ចេកទេស នៃមន្ទីរកសិកម្មខេត្តទាំងបួន។

**រៀបរៀងដោយៈ**

**លោក ពិត ខុនហែល** អ្នកជំនាញផ្នែកក្សេត្រសាស្ត្រ/បន្លែ របស់គម្រោង TSTD

ទូរស័ព្ទៈ 012 585 892

អ៊ីម៉ែលៈ khonhel@gmail.com

## ១. សេចក្តីផ្តើម

ដីស្រែទំនាបស្រូវវស្សាភាគច្រើន ត្រូវបានប្រើសម្រាប់តែដំណាំស្រូវ ប៉ុណ្ណោះ ទោះបីជា មានសំណើមក្នុងដី និង ទឹកអាចស្រោចស្រពបន្ថែម សម្រាប់ដំណាំរួមផ្សំរយៈពេលខ្លី ក៏ដោយ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំ ចុងក្រោយនេះ មានការផ្សព្វផ្សាយជម្រុញ ឱ្យកសិករដាំដំណាំឆ្លងរដូវរយៈពេលខ្លី (ដូចជា ឪឡឹក បន្លែ សណ្តែកបាយ ពោត ...) លើដីស្រែ ។ ក្នុងន័យជម្រុញដំណាំរួមផ្សំបង្កើនរដូវនេះ គម្រោង TSTD អនុវត្តកម្មវិធីបានធ្វើបង្ហាញ និងបណ្តុះបណ្តាលបច្ចេកទេសដាំដំណាំរួមផ្សំ[1] (សណ្តែកបាយ) លើដីស្រែវស្សា ក្នុងគោលបំណង៖

- បង្ហាញបច្ចេកទេសដាំដំណាំសណ្តែកបាយ បង្កើនរដូវ មុន ឬ ក្រោយស្រូវវស្សាលើដីស្រែទំនេរ តាមតំបន់មានសំណើមសមស្រប ដើម្បីបង្កើនផលិតភាពដីស្រែ។
- បង្កើនប្រភពចំណូលដល់កសិករ និង ជីជាតិដី

## ២. ការដាំដំណាំសណ្តែកបាយ

### *២-១. ពូជសណ្តែកបាយដែលនិយមប្រើប្រាស់*

សណ្តែកបាយមាន ២ ប្រភេទ គឺប្រភេទដែលមានសំបកផ្លែព៌ណខ្មៅនៅពេលទុំ និង ប្រភេទដែលមានសំបកផ្លែព៌ណប្រផេះ នៅពេលទុំ ។ សណ្តែកបាយមានសារៈប្រយោជន៍ច្រើនសំរាប់ធ្វើជាចំណីអាហាររបស់មនុស្ស និង ប្រភពចំណូល ។ វាជាដំណាំ ដែលអាចទាញយកអាសូតពីបរិយាកាសដោយខ្លួនឯង និងជួយបង្កើនជីជាតិដីផងដែរ ។ កសិករអាចដាំដំណាំនេះ នៅក្នុងស្រែមុនដំណាំស្រូវវស្សា ឬ នៅក្រោយពេលប្រមូលផលស្រូវរួច ភ្លាមៗ នៅពេលដែលដីស្រែ នៅមានសំណើមនៅឡើយ ពីព្រោះដំណាំនេះត្រូវការទឹកតិចតួច ក្នុងមួយវដ្តជីវិតរបស់វា។




[1] ក្នុងចំណោមដំណាំបានសាកល្បង មាន សណ្តែកបាយ ពោតផ្អែម បន្លែ ឪឡឹក។




## ២-២. *ការជ្រើសរើសពូជ និងការរៀបចំគ្រាប់មុនដាំ*

កសិករ ត្រូវប្រើពូជសុទ្ធល្អ ធន់នឹងជម្ងឺ ពូជធន់នឹងជម្ងឺឫស មានអត្រាដំណុះខ្ពស់ លើសពី ៨៥ ភាគរយ ផ្តល់ទិន្នផលខ្ពស់ និងជាពូជសមស្របតាមតំរូវការទីផ្សារ ។

មុនពេលដាំត្រូវជ្រើសរើសគ្រាប់អោយបានល្អ ចៀសវាងគ្រាប់ដែលមានការបំផ្លាញពីសត្វល្អិត ចង្រៃ និងជម្ងឺ ។ មានពូជសណ្តែកបាយច្រើនណាស់ ដែលកំពុងដាំដុះនិង លក់នៅទីផ្សារប្រទេសកម្ពុជា ដូចជាពូជក្នុងស្រុកដែលយើងស្គាល់ ពូជដែលរំដោះដោយវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្ម កម្ពុជា (CARDI) មានពូជ ស៊ីអឹមប៊ី-១ ស៊ីអឹមប៊ី-២ និង ស៊ីអឹមប៊ី-៣ និង ពូជនាំចូលពីប្រទេសជិតខាង ។

## ២-៣. *ការរៀបចំធ្វើជីកំប៉ុស្ត*

ដំណាំសណ្តែកបាយ ក៏ដូចជាដំណាំឯទៀតដែរ ត្រូវការសារធាតុចិញ្ចឹមពីដី។ ប្រភពសារធាតុ ចិញ្ចឹមមួយ បានមកពីការដាក់ជីធម្មជាតិ មានដូចជា លាមកសត្វ ជីកំប៉ុស្ត ជាដើម។ ជីកំប៉ុស្ត មានទម្រង់ ជាកំប៉ុស្តគោក និង កំប៉ុស្តទឹក។ កំប៉ុស្តគោក អាចធ្វើ បានច្រើនរបៀប។ ខាងក្រោមនេះ ជាវិធីមួយ អាចធ្វើជីកំប៉ុស្ត ឆាប់បានប្រើ។

### ២.៣.១. *វត្ថុធាតុផ្សំធ្វើជីកំប៉ុស្តគោក*

សមាសធាតុ និង រូបមន្តលាយ ធ្វើជីកំប៉ុស្តគោកគឺ ៖

| | |
|---|---|
| លាមកគោ ឬ ក្របីពុកផុយ | ១ ភាគ |
| ផេះអង្កាម ឬ ធ្យូងអង្កាម | 0,៥0 ភាគ |
| កំបោរស | 0,0៥ ភាគ |

ថង់ប្លាស្ទិចថ្លាមាន២ស្រទាប់ធំ ឬ តូច អាស្រ័យលើបរិមាណដី ដែលយើងត្រូវផលិត បើថង់ច្រកដីរួច មាន កំពស់ ១,៥ម៉ែត្រ និង ដ្យាម៉ែត្រ (ឬ ធ្មេញឈើ) ២,៥ ម៉ែត្រ គឺអាចផលិតបានដីចំនួន ១ តោន។

ស្រោចទឹកផ្សើម នៅពេលលាយសារធាតុផ្សំចូលគ្នា។

<u>ឧទាហរណ៍:</u>

| | |
|---|---|
| លាមកសត្វ (គោ ក្របីពុកផុយ) | ១០០ គីឡូក្រាម |
| ផេះអង្កាម ឬ ធ្យូងអង្កាម | ៥០ គីឡូក្រាម |
| កំបោរស | ៥ គីឡូក្រាម |

### *២.៣.២. វិធីធ្វើដីកំប៉ុស្តគោក*

ត្រៀមសម្ភារៈដែលត្រូវការ រួមមាន តង់កៅស៊ូសម្រាប់ក្រាល ថង់ប្លាស្ទិចថ្លាមាន២ស្រទាប់សម្រាប់ច្រកដី ចប ប៉ែល បង្គី ជញ្ជីង។ល។ ចំពោះលាមកគោក្របី ត្រូវយកលាមកគោក្របី (ឬ កាកសំណល់ឡជីវឧស្ម័ន) ដែលស្ងួត ឬ សើមតិចៗហើយ ជ្រោយបំបែក រែងនឹងកញ្ច្រែង និងរើសកំទេចកំទីថង់ប្លាស្ទិច និង វត្ថុរឹង មិនរលាយផ្សេងៗ ចេញឱ្យស្អាត។

ចាក់វត្ថុធាតុផ្សំទាំង ៣ ចូលគ្នា នៅលើតង់កៅស៊ូ ដែលបានក្រាលលាយច្របល់ វាចូលគ្នាឱ្យសព្វល្អ តាមរូបមន្តខាងលើ ដោយមានស្រោចទឹក ឱ្យជោគល្មមចងក្របួចមាត់ថង់ប្លាស្ទិចថ្លាម្ខាងរួចដាក់បញ្ច្រាស (ខាងចង នៅក្រោម ធ្វើជាបាតថង់) ហើយជ្រើសរើសទីតាំងដាក់ថង់ដែលអាចដាក់ត្រូវកំដៅថ្ងៃបានល្អ ពេញមួយថ្ងៃ ។

ច្រកដីដែលលាយច្របល់គ្នារួច ចូលក្នុងថង់ប្លាស្ទិចថ្លា ហើយគៀរពង្រាយឱ្យពេញបាតថង់ បន្ទាប់ពីច្រកពេញ (ត្រឹមកម្រិតអាចក្របួចបាន) ត្រូវចំហរមាត់ថង់ ហាលថ្ងៃ ឱ្យបានយ៉ាងតិច ២ ម៉ោង មុននឹងចងក្របួចមាត់ថង់ ខាងលើ។

ចងមាត់ថង់ឱ្យជិតល្អ ហើយទុកហាលកណ្តាលថ្ងៃនៅទីតាំងនោះយ៉ាងតិច ១៤ថ្ងៃទើបអាចប្រើបាន។ ទុកកាន់តែយូរ កាន់តែប្រសើរ។



## ២-៤. *វិធីសាស្ត្រដាំដុះ*

ដំណាំសណ្តែកបាយ អាចដាំដុះពេញ ១ឆ្នាំ នៅតាមដីចំការតំបន់ខ្ពង់រាប តាមតំបន់តាមដងទន្លេ តាមដីកោះ ដីស្រែ និង ជាដំណាំឆ្លាស់ជាមួយ ដំណាំពោត សណ្តែកដី  ដំឡូងមី ដាំនៅតាមចន្លោះដើមកៅស៊ូដែលនៅតូចៗ ដោយការបុកដាំជាជួរ ការឆូតដាំជាចង្អូរ និងការដាំដោយព្រួសលើដីដែលភ្ជួររួចហើយរាស់លប់ ។

កសិករ ក៏អាចធ្វើការដាំដុះបាននៅលើដីស្រែ ក្រោយពីការច្រូតកាត់ប្រមូលផលស្រូវវស្សាហើយភ្លាមៗ នៅពេលដែល ដីស្រែនៅមានសំណើមនៅឡើយ គឺនៅក្នុងអំឡុងពីចុងខែ វិច្ឆិកា ដល់ ខែមករា ហើយប្រមូលផលនៅរវាងក្នុងខែមករា និង ខែមីនា ។

ការរៀបចំដីបានល្អ  និងដីនៅមានសំណើមគ្រប់គ្រាន់ គ្រាប់ចាប់ផ្តើមដុះទូលដីមកខាងលើក្រោយពីដាំបាន ៣ ថ្ងៃ ។  ចាប់ពីពេលដុះពន្លក  រហូតដល់អាយុ ១៥ថ្ងៃសណ្តែកបាយមានការដុះលូតលាស់យឺត តែចាប់ពីអាយុ ២០ ថ្ងៃឡើងទៅ ចាប់ផ្តើមមានការដុះលូតលាស់លឿន ។  យើងអាចដាំសណ្តែកបាយ តាមវិធី ៣ យ៉ាង ៖

### ២-៤-១. *ការដាំដុះដោយបុកជារណ្តៅ*

- ត្រូវដាំសណ្តែកបាយចន្លោះពីជួរមួយទៅជួរមួយ ចំងាយ ៥០សង់ទីម៉ែត្រ (៥តឹក)

- ចន្លោះពីរណ្តៅមួយទៅរណ្តៅមួយ ២៥សង់ទីម៉ែត្រ (២តឹកកន្លះ)
- ក្នុងមួយរណ្តៅ ប្រើគ្រាប់ពូជ ពី ៤ ទៅ ៥ គ្រាប់
- ការដាំរបៀបនេះត្រូវការគ្រាប់ពូជចំនួន ៣០ គីឡូក្រាម ក្នុងមួយហិកតា។ ក្រោយពីដុះបាន ១៥ ថ្ងៃ ត្រូវដកចោល ខ្លះ ទុក តែពី ២ ទី ៣ ដើមប៉ុណ្ណោះ ក្នុងមួយគុម្ព/រណ្តៅ។




### *២-៤-២. ការដាំដោយឆូតគន្លងជាជួរ*

ចំណែកការដាំឆូតដាំជាចង្អូរ ត្រូវការគ្រាប់ពូជពី ៣០ ទៅ ៤០ គីឡូក្រាម ក្នុង១ហិកតា ។ ក្រោយពីភ្ជួរដីរួចរាល់ គេចាប់ផ្តើមភ្ជួរធ្វើជាគន្លងសំរាប់ដាក់គ្រាប់ គឺៈ

- ចន្លោះជួរពី ៥០ ទៅ ៦០ សង់ទីម៉ែត្រ (ឬ ពី៥ ទៅ ៦តឹក)
- ចន្លោះគុម្ព ពី១០ ទៅ ២០ សង់ទីម៉ែត្រ
- ក្នុង ១ គុម្ព ទុកពី ២ ទៅ ៣ ដើម
- ជំរៅកប់គ្រាប់ ពី ២ ទៅ៣ សង់ទីម៉ែត្រ

ការដាំតាមវិធីនេះត្រូវការគ្រាប់ពូជប្រមាណ ពី ២៥ ទៅ ៣០ គីឡូក្រាម ក្នុងដី១ហិកតា ហើយ អាចដាំដុះឆ្លាស់មុខដំណាំជាមួយ អំពៅ ពោត...។ល។




### ២-៤-៣. ការដាំដោយព្រួស

វិធីនេះគេនិយមអនុវត្តនៅតាមតំបន់ដងទន្លេ ពេលដីចំការនៅសើមល្អ។ បន្ទាប់ពីបាចរួច ត្រូវរាស់លប់គ្រាប់ មួយ ឬ ពីរសារ ប៉ុន្តែទាមទារឱ្យមានការដុះស្រុះគ្នានៃគ្រាប់ពូជ ដើម្បីប្រណាំងប្រជែងស្មៅចង្រៃ។ ក្នុងផ្ទៃដី ១ ហិកតា ត្រូវការពូជ ពី ៣០ ទៅ ៤០ គីឡូក្រាម ។




### ២-៥. ការដករំលស់កូន

ក្រោយពីដាំបាន រយៈពេល ពី១០ ទៅ ១៥ថ្ងៃ គេត្រូវដករំលស់កូនសណ្តែកបាយ ដោយទុកតែដើមណាដែលថ្លោស និងរឹងមាំជាងគេ ចំនួនពី ២ ទៅ ៣ដើម ក្នុង១គុម្ព និងត្រូវដកស្មៅចង្រៃឱ្យបានស្អាត ដើម្បីចៀសវាងការដណ្តើមជីជាតិពីដំណាំ ដែលធ្វើឱ្យដំណាំដុះលូតលាស់យឺត ។






## ២-៦. ការប្រើប្រាស់ជី

### ២-៦-១. ជីគីមី

ការប្រើប្រាស់ជីតាមបច្ចេកទេស និងត្រឹមត្រូវតាមពេលវេលា ធ្វើឱ្យដំណាំលូតលាស់ល្អ និងទទួលបានទិន្នផលខ្ពស់ ។ ជីដែលគេនិយមប្រើលើដំណាំសណ្តែកបាយ គឺជីអ៊ុយរ៉េ ដេអាប៉េ និងប៉ូតាស្យូម ។ ការប្រើប្រាស់ជី ចែកចេញជា ២ ដំណាក់កាល គឺ ជីដេអាប៉េ និងប៉ូតាស្យូម (១០០ភាគរយ) ដាក់ទ្រាប់បាតមុនពេលដាំ ។ ចំណែក ជីអ៊ុយរ៉េ ដែលនៅសល់ ប្រើសម្រាប់ដាក់បំប៉នមួយលើកទៀត ក្រោយពីដាំបាន ២០ថ្ងៃ ដើម្បីជំរុញការលូតលាស់ និងបង្កើនកំពកឫស ។ ចំណែកដីដែលជាប្រភេទដីខ្សាច់ ដូចជាក្រុមដីប្រទះឡាង និងដីព្រៃខ្មែរ គេចាំបាច់ត្រូវប្រើជីអ៊ុយរ៉េក្នុងបរិមាណច្រើនដើម្បីឱ្យដំណាំលូតលាស់ល្អ និង បង្កើនកំពកឫស ។ ជីត្រូវដាក់ឃ្លាតពីគល់ចំងាយពី ៥ ទៅ ១០សង់ទីម៉ែត្រ រួចពូនដីលប់ឱ្យជិត ដើម្បីទប់គល់ដំណាំផង និងការពារជីមិនឱ្យបាត់បង់តាមរយៈការហើរ ទៅក្នុងបរិយាកាស និងការហូរច្រោះដោយសារទឹកផង ។

| ឈ្មោះជី | កម្រិតជីទៅតាមក្រុមដី (គីឡូក្រាម ក្នុង ១ ហិកតា) | | |
|---|---|---|---|
| | ព្រៃខ្មែរ ប្រទះឡាង (ដីខ្សាច់ ល្បាយខ្សាច់) | កំពង់សៀម ឡាបានសៀក ទួលសំរោង (ដីល្បាយអិដ្ឋ) | កៀនស្វាយ (ដីល្បាយ) |
| **អ៊ុយរ៉េ** | ១៤៥ | ១៥ | ១៣ |
| **ដេអាប៉េ** | ១៣០ | ១៥៧ | ១៣៣ |
| **ប៉ូតាស្យូម** | ៥០ | ៥៨ | ៦៧ |








### ២-៦-២. ជីលាមកគោ និងកំប៉ុស្ត

ជីលាមកគោ និងជីកំប៉ុស្ត អាចប្រើនៅពេលទ្រាប់បាតក្នុងកម្រិត ៥តោន ក្នុង ១ហិកតា ឬ ០,៥ គីឡូក្រាម ក្នុង ១ ម៉ែត្រការ៉េ ។

 

### ២-៧. *ការកំចាត់ស្មៅចង្រៃ*

ការកំចាត់ស្មៅចង្រៃ ត្រូវធ្វើនៅរយៈពេល ១៥ និង ៣០ថ្ងៃក្រោយពីដាំ ។ បើហួសពេលនេះវានាំឱ្យប៉ះពាល់ដល់ប្រព័ន្ធឫស និង នាំដល់ការជ្រុះផ្កា ។

### ២-៨. *ជម្ងឺ និងសត្វល្អិតលើដំណាំសណ្តែកបាយ វិធីការពារ និង កំចាត់*

សត្វល្អិតដែលកើត លើដំណាំសណ្តែកមាន ដង្កូវរុយ ដង្កូវស្នែង ចៃសណ្តែក ពីងពាងក្រហម ដង្កូវកាត់ដើមកាត់ស្លឹក ស្រឹង រុយកូនសណ្តែក ដង្កូវស៊ីរុងក្បូរ ដង្កូវស៊ីផ្លែ ។ គេអាចកំចាត់សត្វល្អិតទាំងនេះ ដោយប្រើថ្នាំគីមីមួយចំនួន ឬ ប្រើវិធានការ អាយភីអឹម ។

ជម្ងឺសំខាន់ៗដែលកើតលើដំណាំសណ្តែកមាន ជម្ងឺអុតត្នោតលើដំណាំសណ្តែក (Cercospora Leaf Spot) ជម្ងឺ រួញលឿងលើដំណាំសណ្តែក (Mungbean yellow mosaic virus) ជម្ងឺ រលួយគល់ និង ឫស (Root and basal stem rot) និងជម្ងឺ រលួយខ្មៅ (Charcoal rot) ។

#### ២-៨-១. *ជម្ងឺសណ្តែកបួស*

ជម្ងឺនេះច្រើនកើតលើដើមសណ្តែកដែលចាប់ពីអាយុមាន ១ខែ ក្រោយដំណុះ រហូតចេញផ្កា។

**រោគសញ្ញា ៖** ស្លឹកបាត់បង់ពណ៌បៃតងបន្តិចម្តងៗ ពីចុងត្រួយមកក្រោម ដោយប្រែជាពណ៌លឿង នៅពេលជម្ងឺ រាតត្បាតពេញទំហឹង គ្រប់សរីរាង្គប្រែជាពណ៌លឿង ហើយងាប់តែម្តង។ ផ្លែ ក្បូរនៃដើមដែលកើតជម្ងឺនេះអាចមានគ្រាប់ តិចតួច ឬ គ្មានតែម្តង។ សណ្តែកបួស គឺឆ្លងពីដើមមួយទៅដើមមួយ ពីចំការមួយទៅចំការមួយ និង ពីតំបន់មួយទៅតំបន់មួយ ដោយភ្នាក់ងារបង្កជម្ងឺ និងវីរុស និងសត្វល្អិតជញ្ជូនជំរមានដូចជាពពួកចៃ ជាដើម។

**ការការពារ និង កំចាត់**

- ជ្រើសរើសពូជធន់នឹងជម្ងឺនេះ
- ដាំដុះស្របពេលដែលប្រជាជនក្នុងមូលដ្ឋានដាំ
- ជម្រះស្មៅឱ្យបានស្អាត
- ដកដើមកើតជម្ងឺចោល ដោយដុត ឬ កប់
- បាញ់ថ្នាំកំចាត់សត្វល្អិត (ថ្នាំផ្សំពីរុក្ខជាតិ ឬ ថ្នាំគីមី)



## ២-៨-២. ជម្ងឺអុចពណ៌ត្នោតលើស្លឹកសណ្តែកបាយ

ជម្ងឺនេះច្រើនកើតមាននៅរដូវវស្សា មានស្នាមអុចមូលៗពណ៌ត្នោតនៅលើស្លឹក ។ ជួនកាល មានពណ៌ក្រម៉ៅ ឬ ឈាមជ្រូក ដែលមានអង្កត់ផ្ចិតប្រវែង ៣ មីលីម៉ែត្រ បន្ទាប់មកចំណុចកណ្តាល ប្រែពណ៌ទៅជាប្រផេះ ហើយវាក៏ងាប់ អាចជ្រុះ មកដីបន្សល់ ទុកតែប្រហោងកណ្តាលតូចៗ។ ជម្ងឺអុចត្នោតរាលដាលយ៉ាងឆាប់រហ័ស កាលណាសីតុណ្ហភាព ប្រែប្រួល ពីត្រជាក់ទៅក្តៅសើម ដោយស្លឹកសណ្តែកទាំងឡាយត្រូវក្រៀមស្វិតជ្រុះទៅដី ។

**វិធានការការពារ:**

- ប្រើពូជធន់នឹងជម្ងឺ
- យកគ្រាប់សណ្តែកលាយជាមួយថ្នាំផ្សិតមុនពេលដាំ
- ទុកដីចោលទំនេរពីដំណាំដែលជាជម្រកនៃជម្ងឺនេះចំនួន ៣ ឆ្នាំ ដើម្បីបន្ថយការរាតត្បាត
- ការប្រើជីគ្រប់គ្រាន់ សំណើមសមស្របដល់ការលូតលាស់ មានសន្ទុះលឿនជៀសផុតពីការបំផ្លាញនៃជម្ងឺ នេះ ។ ជម្ងឺនេះរាតត្បាតក្នុងរយៈពេលសីតុណ្ហភាពចុះទាប ។

## ២-៨-៣. សត្វល្អិតបំផ្លាញជញ្ជក់ជ័រ

### ២-៨-៣-១. ចៃ

ចៃមានពណ៌ខ្មៅ ឬពណ៌ត្នោតក្រម៉ៅ មានទំហំ ១,៥ ទៅ ២មីលីម៉ែត្រ ។ ខ្លួនវាទន់ៗ ងាយនឹងបែកស្លាប់ណាស់ ពេលទើបនឹងញាស់វាគ្មានស្លាបទេ ។

**ការបំផ្លាញ ៖**

នៅពេលសណ្តែកបាយស្ថិតនៅក្នុងវគ្គបែកមែក (អាយុ២៣ថ្ងៃ ) ចៃចាប់ផ្តើមបំផ្លាញយ៉ាងខ្លាំង ដោយជញ្ជក់យកទឹកជីជាតិលើសរីរាង្គខ្ចីពីដើម ត្រួយ និងមែក ។ វាធ្វើឱ្យត្រួយសណ្តែករួញរមូរ ការលូតលាស់ ខ្សោយ។ តាមធម្មតា គេសំគាល់ឃើញថា ពេលដែលមានចៃច្រើន ក៏មានស្រមោចទៅរោមជាមួយចៃនេះ ជញ្ជក់យកជាតិសើមម៉្យាងស្អិតៗ ដែលចៃនេះបញ្ចេញមកប្រលាក់ជាប់លើស្លឹក ។

**វិធានការការពារ ៖**

ត្រាំកំទេចថ្នាំខ្លាំង ១ គីឡូក្រាម សំរាប់ត្រាំទឹក ១ លីត្រ រយៈពេល ១២ ម៉ោង ទើបយកទឹកនោះទៅច្រោះ រួចលាយ ជាមួយទឹក ២០ លីត្រ ហើយយកសាប៊ូ ២០ ក្រាមលាយក្នុងទឹកថ្នាំនោះ កូរឱ្យសព្វ ទើបបាញ់ ។

ប្រើថ្នាំពុលគីមី (ប្រភេទថ្នាំជ្រាប )



**២-៨-៣-២. ពីងពាងក្រហម**

មានខ្លួនតូចៗ មើលនឹងភ្នែកទទេសឹងតែមិនឃើញ ខ្លួនវាមានពណ៌ក្រហម មានជើងប្រាំបី ។ វាចូលចិត្ត រស់ នៅផ្នែកខាង ក្រោមនៃស្លឹក ។

**ការបំផ្លាញ ៖** ពីងពាងក្រហមជញ្ជក់ជ័រ ធ្វើអោយស្លឹកសណ្តែក មានពណ៌លឿងអុចខ្មៅតូចៗ ដែលបណ្តាល ឱ្យលែងលូតលាស់ ។

**វិធានការការពារ ៖**

- បាញ់ថ្នាំផ្សំពីរុក្ខជាតិ
- ថ្នាំគីមី (ហ្វូសឌ្រីន ៣ គ.ក្រ ក្នុង ១ ហិកតា )

### *២-៨-៤. សត្វល្អិតចោះស៊ីផ្លែ និង ផ្កា*

#### ២-៨-៤-១. ដង្កូវឆ្នូតមានរោម

ដង្កូវមានពណ៌ប្រផេះ ឆ្នូតខ្មៅតូចនៅតាមបណ្តោយខ្លួនវា និងមានរោមឆ្មារៗ នៅពាសពេញលើខ្លួនវាទៀតផង។ ទំហំខ្លួនប៉ុនចុងចង្កឹះ មានប្រវែង ៣៥មីលីម៉ែត្រ ។ មេអំបៅជាប្រភេទសត្វល្អិត មានពណ៌ខ្មៅដុំៗ ស្ថិតនៅពាសពេញលើស្លាបខាងលើវា ទទឹងកាងស្លាបមានប្រវែងប្រមាណ ៣០មីលីម៉ែត្រ ហើយមានពងពី១៨០ ទៅ២០០ (១សំបុក) ស្ថិតនៅផ្នែកខាងក្រោមស្លឹកជាកញ្ចុំមានសំឡីពណ៌សគ្របការពារលើពង ហើយញាស់ក្នុងរយៈពេលពី៧ ទៅ៩ថ្ងៃ។

**ការបំផ្លាញ ៖** ដង្កូវឆ្នូតមានរោមដែលទើបញាស់ចាប់បំផ្លាញដោយចោះគ្រាប់ស៊ីនៅពេលដែលផ្លែសណ្តែក នៅខ្ចី ហើយវានៅបែកផ្សេងពីគ្នា ។ ដង្កូវប្រភេទនេះចេញរកស៊ីពេលល្ងាចត្រជាក់ និងពេលព្រឹក ដល់ពេលក្តៅវាចុះមកជ្រកលាក់ខ្លួននៅក្រោមផ្ទៃស្លឹក ។ ដង្កូវនេះអាចស៊ីដំណាំច្រើនប្រភេទ ដូចជា កប្បាស ពោត ថ្នាំជក់ និងបន្លែ ផ្សេងៗទៀត ។

**វិធានការការពារ ៖**

គេអាចសំលាប់ដង្កូវឆ្នូតមានរោមដោយប្រើថ្នាំផ្សំពីរុក្ខជាតិ ឬ ថ្នាំពុលគីមី ។



### ២-៨-៤-២. ដង្កូវមូរស្លឹក



## ២-៨-៥. សត្វល្អិតចុចជញ្ជក់ផ្លែ

### ២-៨-៥-១. សង្កើចពណ៌បៃតង

មានខ្លួនសំប៉ែត មានស្លាបលើរឹងពាក់កណ្តាល និងស្តើងទន់ពាក់កណ្តាល មានពណ៌ស្លឹកឈើ ស្លាបក្រោមស្តើងថ្លាដូចប្លាស្ទិច បណ្តោយខ្លួនប្រវែង ១៥មីលីម៉ែត្រ ហើយមានស្នែងស្រួចពីរត្រង់ទៅមុខ នៅលើ ក្បាលរបស់វា ។

**ការបំផ្លាញ ៖** វាចូលចិត្តជញ្ជក់គ្រាប់នៃផ្លែ ធ្វើអោយសណ្តែកស្កកគ្មានគ្រាប់ ។

**វិធានការការពារ ៖** ត្រូវប្រើថ្នាំផ្សំពីរុក្ខជាតិ ឬ ថ្នាំពុលគីមី ។



## *២-៩. ការប្រមូលផល*

ផ្លែសណ្តែកបាយចាប់ផ្តើមទុំនៅពេលមានអាយុពី៥០ ទៅ៧០ថ្ងៃ ឬ នៅរយៈពេល ៣០ថ្ងៃ ក្រោយពេលចេញផ្កា អាចបេះប្រមូលផលបាន នៅពេលទុំសំបកក្បូរប្រែពីព៌ណបៃតងក្រម៉ៅទៅជាខ្មៅ ឬ ព៌ណលឿងប្រផេះ សំបកក្បូរស្ងួតក្រៀម គ្រាប់ក្នុងផ្លែរលុង គ្រាប់ឡើងរឹង ហើយភ្លឺរលោង និងសំណើមគ្រាប់មានប្រមាណពី ២០ ទៅ ២៥% ។ ចាប់ពីអាយុ ៧០ថ្ងៃឡើងទៅ ស្លឹកទាំងអស់ប្រែព៌ណលឿង និងក្រៀមជ្រុះតែម្តង។ ដោយការទុំរបស់ដំណាំនេះ ពុំមានលក្ខណៈ ស្រុះគ្នា គេអាចប្រមូលផលពី ២ ទៅ ៣ លើក ។

លើកទី១៖ នៅពេលសណ្តែកទុំបានប្រមាណពី ៥០ ទៅ ៧០%
លើកទី២៖ នៅរយៈពេល១៥ថ្ងៃក្រោយប្រមូលលើកទី១
លើកទី៣៖ អាចមានលើកទី៣ រយៈពេលពី ៧ ទៅ ១០ថ្ងៃ ក្រោយប្រមូលលើក២ ។

ការប្រមូលផលគួរធ្វើនៅពេលព្រឹក ពីព្រោះនៅពេលថ្ងៃរសៀល មានអាកាសធាតុក្តៅ នាំឱ្យងាយរបើកសំបកជ្រុះគ្រាប់ ។




## *២-១០- ការហាលសម្ងួតក្បួរ*

បន្ទាប់ពីបេះផ្លែពីចំការហើយ គេយកផ្លែទាំងនោះទៅហាលរយៈពេលពី ៥ ទៅ១០ ថ្ងៃ ហើយគេវាយផ្លែនោះនឹងដំបងឈើ ដើម្បីឱ្យបែកគ្រាប់(វាយល្មមៗ ) រួចគេសំអាតសំបកនោះចេញ ។ ក្នុងករណីគ្រាប់ចំណីគេអាចប្រមូលទុកក្នុងជង្រុក ឬបាវតែម្តងតែបើករណីជាគ្រាប់សំរាប់ទុកពូជ គេត្រូវហាលបន្ថែមរយៈពេលពី២ ទៅ ៣ថ្ងៃទៀត ដើម្បីឱ្យគ្រាប់ស្ងួតល្អ ទើបអាចទុកពូជបាន ។





### ២-១១- ការទុកដាក់ ថែទាំគ្រាប់ពូជ

ដើម្បីទុកដាក់គ្រាប់អោយមានសុវត្ថិភាព ការរក្សាទុកដាក់គ្រាប់ពូជសម្រាប់ប្រើប្រាស់ នៅរដូវបន្ទាប់ គឺគ្រាប់ពូជត្រូវមានសំណើមពី ១២ ទៅ ១៣% ហើយត្រូវរក្សាទុកដាក់នៅកន្លែង ដែលគ្មានសត្វល្អិត គ្មានខ្យល់ចេញចូល ឬទុកនៅក្នុងធុងបិទជិត ឬ អាចរក្សាទុកដោយប្រើប្រាស់ថ្នាំការពារសត្វល្អិត ។





## ៣. ការកត់ត្រាចំណាយចំណូលផលិតកម្ម និង វិភាគសេដ្ឋកិច្ច

### ៣.១. ការកត់ត្រាចំណាយចំណូលផលិតកម្ម

ការកត់ត្រាទុកនូវតួរលេខចំណាយចំណូល មានសារៈសំខាន់ណាស់ ។ មានហេតុផលជាច្រើន ដែលគេចាំបាច់ត្រូវកត់ត្រាជាប្រចាំ ពីចំណាយចំណូលផលិតកម្ម ។ ខាងក្រោម ជាហេតុផលចំបងៗមួយចំនួន ៖

- ប្រសិនបើគ្មានការកត់ត្រាពីអ្វីដែលត្រូវបានចំណាយ ហើយអ្វីដែលបានចំណូលនោះទេ យើងនឹងមិនអាចដឹងបានទេ ថាតើ មុខជំនួញរបស់យើងខាត ឬ ចំណេញ? ចូរចងចាំថា ការទទួលបានប្រាក់ចំណូលរាល់ថ្ងៃ មិនមានន័យថា យើងបានទទួលប្រាក់ចំណេញនោះទេ ។

- ប្រសិនបើយើងដឹងច្បាស់ពីមុខចំណាយ និង មុខចំណូលច្បាស់លាស់ យើងអាចរិះរកវិធីដើម្បីគ្រប់គ្រងជំនួញ ឱ្យបានកាន់តែល្អ កាន់តែបានចំណេញច្រើន។
- កំណត់ត្រាអាចត្រូវប្រើប្រាស់សម្រាប់ធ្វើផែនការចំណាយនៅពេលអនាគត ព្រោះយើងអាចដឹងពីតំលៃ និង ធនធានដែលត្រូវចំណាយ ។

គោលដៅចំបងនៃធ្វើជំនួញ ឬ ផលិតកម្មអ្វីមួយ គឺរកបានចំណេញ និង កាន់តែចំណេញច្រើន ។ ប្រាក់ចំណេញ ជា ផលសង (ឬ ភាពខុសគ្នាជាវិជ្ជមាន) រវាង **ប្រាក់ចំណូល** (បានមកពីការលក់ផលិតផល ឬ សេវាកម្ម) និង **ប្រាក់ចំណាយទាំងអស់** ។ ចំណាយ អាចបែងចែកជា ២ ប្រភេទ គឺ ៖

(១) **ចំណាយថេរ** (មិនប្រែប្រួល [2]) គឺជា ចំណាយមូលធន ដូចជា ដី សំណង់ គ្រឿងចក្រ ឧបករណ៍កសិកម្ម ឃ្លាំង សម្ភារៈសាងសង់ទ្រើងត្រសក់ ប្រព័ន្ធស្រោចស្រពដំណក់ទឹក រោងបណ្តុះផ្សិត ទ្រុងមាន់ គ្រឿងចក្រ...... ដែលមានតំលៃ (ត្រូវកាត់រំលស់) ជាប្រចាំ ទោះជាមានការផលិត ឬក៏ គ្មាន ក៏ដោយ ។ ដោយសារឧបករណ៍ និងសម្ភារៈ ក្នុងមុខចំណាយថេរទាំងនេះ អាចប្រើបានច្រើនដង (ប្រើម្តង មិនអស់) ហើយ អាចប្រើនៅក្នុងផលិតកម្ម សារក្រោយៗទៀតនោះ គេត្រូវគិតរំលស់វា ជាច្រើនសារ/ដង ។ ការកំណត់ចំនួនសាររំលស់ថ្លៃឧបករណ៍ និង សម្ភារៈ ក្នុងប្រភេទចំណាយថេរនេះ អាចគិតបានច្រើនបែប ដូចជា តាម ចំនួនសារ (ដង) ផលិតកម្ម តាមអាយុកាល (រយៈពេល) អាចនៅប្រើបានរបស់វា ...... ។
(២) **ចំណាយប្រែប្រួល** គឺជាប្រភេទចំណាយជាក់ស្តែងសម្រាប់ការផលិត ផលិតផល ឬសេវាកម្មអ្វីមួយ។ ការចំណាយប្រភេទនេះ រួមមាន វត្ថុធាតុដើម ដូចជា គ្រាប់ពូជ ជី ថ្នាំ កំបោរស ការរៀបចំដី ថ្លៃបូមទឹកស្រោចស្រព ពលកម្ម ...... ដែលត្រូវការ ចាំបាច់សម្រាប់ផលិតរបស់ ឬ ផលិតផលអ្វីមួយ (ដូចជា ផ្សិតចំបើង មាន់ ជ្រូក......) ។

ដើម្បីឱ្យដឹងច្បាស់ ថាតើគោលដៅជោគជ័យជំនួញ សម្រេចបានត្រឹមណានោះ គេត្រូវការព័ត៌មានជាចាំបាច់ ដែលមិនអាចរកបាន ក្រៅតែពីការកត់ត្រាជាប្រចាំ និង បានត្រឹមត្រូវរបស់យើងនោះឡើយ ។ ការកត់ត្រា អាចផ្តោតលើការប្រមូលព័ត៌មានចាំបាច់ សម្រាប់វិភាគចំណាយ និងចំណេញ និង តម្រង់ទិសមុខរបរ ឬ ផលិតកម្ម តាមពេលវេលា ឲ្យចំ ឆ្លើយតបតម្រូវការទីផ្សារ និង

[2] នៅពេលទិញ ឬសាងសងហើយ (គឺថា បានចំណាយហើយ) ទោះបីប្រើ ឬមិនប្រើក្តី សម្រាប់ការផលិតទំនិញ (ផលិតផល) អ្វីមួយ ក៏ដោយ ក៏គុណភាព (គឺថា វាក្លាយបន្តិចម្តងៗ ទៅជារបស់ចាស់ សឹករេចរិល...... ) ហើយ តំលៃរបស់វា នឹងត្រូវបាត់បង់ បន្តិចម្តងៗ ទៅតាមនោះដែរ។

ទៅអនាគតខាងមុខ ។ ខាងក្រោមនេះ ជាទម្រង់កត់ត្រា[3] សាមញ្ញមួយ ដែលកសិករ អាចប្រើសម្រាប់កត់ត្រាចំណាយ ចំណូលរបស់ខ្លួន ។

ក. តារាងចំណាយ

ឈ្មោះផលិតកម្ម:………………………………………
ថ្ងៃចាប់ផ្តើមផលិតកម្ម:………………………………… ថ្ងៃបញ្ចប់ផលិតកម្ម:………………………

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តំលៃ ១ឯកតា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

ខ. តារាងចំណូល

ឈ្មោះផលិតកម្ម:………………………………………
ថ្ងៃចាប់ផ្តើមផលិតកម្ម:………………………………… ថ្ងៃបញ្ចប់ផលិតកម្ម:………………………

| ល.រ | មុខចំណូល | ឯកតា | ចំនួន | តំលៃ ១ឯកតា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

## ៣.២. ការប្រើប្រាស់ព័ត៌មានប្រមូលបាន សម្រាប់វិភាគចំណាយចំណូលផលិតកម្ម

ដើម្បីទទួលបានព័ត៌មាន ចាំបាច់ ត្រឹមត្រូវ គេត្រូវកំណត់ឲ្យបានច្បាស់ពីមុខចំណាយ និង ចំណូលទាំងអស់ ហើយកត់ត្រាបានជាប្រចាំ និង បានត្រឹមត្រូវពីព័ត៌មាន ដែលបានកំណត់ទាំងនោះ ។ ព័ត៌មានប្រមូលបានទាំងនេះ នឹងត្រូវប្រើសម្រាប់វិភាគសេដ្ឋកិច្ច (គឺ ថ្លៃដើមផលិតផល និង ប្រាក់ចំណេញ) របស់ផលិតកម្មណាមួយ ។ ខាងក្រោមនេះ គឺជា គំរូកត់ត្រា និង វិភាគចំណាយ និង ចំណូលនៃការដាំដំណាំសណ្តែកបាយលើដីស្រែ របស់កសិករ នៅស្រុកស្ទឹងត្រង់ ខេត្ត កំពង់ចាម ។

[3] តាមគំរូ សៀវភៅកត់ត្រាគ្រប់គ្រងកសិដ្ឋានកសិករ របស់ គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាព ជុំវិញតំបន់ទន្លេសាប។

## ការវិភាគសេដ្ឋកិច្ចការដាំដុះដំណាំសណ្តែកបាយលើដីស្រែ

ឈ្មោះកសិករៈ ប៊ួយ កេង ភូមិ សំបូរ ឃុំ សូភាស ស្រុក ស្ទឹងត្រង់ ខេត្ត កំពង់ចាម

ដំណាំៈ សណ្តែកបាយ ពូជៈ ស្ពានីយចំការលើ

ថ្ងៃចាប់ផ្តើមៈ ថ្ងៃទី ០៤ មករា ២០១៣ ថ្ងៃប្រមូលផល ថ្ងៃទី ០៣ មេសា ២០១៣

លើផ្ទៃដីៈ ៤.០០០ ម៉ែត្រការ៉េ

| បរិយាយ | ឯកត្តា | ចំនួន | តម្លៃ/ឯកត្តា | សរុប | ចំនួនសារ រំលស់ | សរុប ក្នុង១រដូវ |
|---|---|---|---|---|---|---|
| **១-ចំណូល** | | | | | | |
| ប្រាក់ចំណូលបានពីលក់គ្រាប់សណ្តែកបាយ | គីឡូក្រាម | 350 | 5.000 | 1.750.000 | - | 1.750.000 |
| ចំណូលសរុប | | 350 | | | | 1.750.000 |
| **២ក-ចំណាយ ប្រែប្រួល** | | | | | | |
| ថ្លៃរៀបចំដី (៤.០០០ ម៉ែត្រការ៉េ ) | សារ | 2 | 50.000 | 100.000 | - | 100.000 |
| គ្រាប់ពូជសណ្តែក | គីឡូក្រាម | 10 | 5.200 | 52.000 | - | 52.000 |
| ជីអិនប៉េកា/ជីគីមី (ប្រភេទ អ៊ុយរ៉េ និងដេអាប៉េ) | គីឡូក្រាម | 20 | 2.400 | 48.000 | - | 480.000 |
| ជីធម្មជាតិ | គីឡូក្រាម | 1.000 | 50 | 50.000 | - | 50.000 |
| ថ្នាំកំចាត់ជម្ងឺផ្សិត និងសត្វល្អិត | លីត្រ | 1 | 20.000 | 20.000 | - | 20.000 |
| កម្លាំងពលកម្មព្រួសគ្រាប់ | នាក់-ថ្ងៃ | 1 | 15.000 | 15.000 | - | 15.000 |
| កម្លាំងពលកម្មធ្វើស្មៅ | នាក់-ថ្ងៃ | 2 | 15.000 | 30.000 | - | 30.000 |
| កម្លាំងពលកម្មដាក់ជីបំប៉ន | នាក់-ថ្ងៃ | 2 | 15.000 | 30.000 | | 30.000 |
| កម្លាំងពលកម្មប្រមូលផល | នាក់-ថ្ងៃ | 4 | 15.000 | 600.000 | | 600.000 |
| កម្លាំងពលកម្មវាយបំបែកសំបក | នាក់-ថ្ងៃ | 2 | 15.000 | 30.000 | | 30.000 |
| កម្លាំងពលកម្មបក់ រោយសម្អាតគ្រាប់ | នាក់-ថ្ងៃ | 1 | 15.000 | 15.000 | - | 15.000 |
| សរុបចំណាយប្រែប្រួល (TVC) | | | | | | 1.422.000 |
| *៣ក-ប្រាក់ចំណេញ ធៀប ចំណាយប្រែប្រួល TVC* | | | - | - | - | 328.000 |
| **២ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | | |
| ចង់កៅស៊ូសំរាប់ធ្វើជីកំប៉ុស្ត | ម៉ែត្រ | 4 | 3.000 | 12.000 | 2 | 6.000 |
| សរុបចំណាយមិនប្រែប្រួល/ថេរ (TFC) | | | | | | 6.000 |
| | | | | | | |
| **២គ-ចំណាយសរុប** ( TC = TVC+TFC ) | | | | | | 1.428.000 |
| *៣ខ-ប្រាក់ចំណេញ ធៀបចំណាយ សរុប TC* | | | | | | 322.000 |

